ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　　ជាតិ　សាសនា　ព្រះមហាក្សត្រ

*****

**********

សំណុំរឿងរដ្ឋប្បវេណី

លេខ: ១១៦　　　　　　　　សាលដីកាប្រជារាស្ត្រខ្មែរ

ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០២　　　　　　តុលាការកំពូល

**សាលដីកា**

លេខ: ១៥៩　　　　　　　　បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៣

ចុះថ្ងៃទី១៧ ខែកក្កដាឆ្នាំ២០០៣　ដោយមានសមាសភាព ដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឌិត មុន្ទី** | ជាប្រធាន |
| ២- លោក | ស៊ិន ឌីម | ជាចៅក្រម របាយការណ៍ |
| ៣-លោក | ជីវ កេង | ជាចៅក្រម |
| ៤- លោក | ប្រាក់ គឹមសាន | ជាចៅក្រម |
| ៥- លោក | ឈឹម ស៊ីផល | ជាចៅក្រម |
| ៦- លោក | យស់ សូខឿន | ជាចៅក្រម |
| ៧- លោក | សោម សិរីវឌ្ឍ | ជាចៅក្រម |
| ៨- លោក | គង់ ភីរុន | ជាចៅក្រម |
| ៩- លោក | ប៉ែន សាវឿន | ជាចៅក្រម |

ក្រឡាបញ្ជី

លោក　　ឡេង វុធ

តំណាងមហាអយ្យការ

លោក　　ឈួន ចាន់ថា　　ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីកាលេខ១១១ "គ" ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០១ នៃសំណុំ រឿងរដ្ឋប្បវេណីលេខ២២ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ រវាង :

-ដើមចោទឈ្មោះ សុខ សារុន (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥៧ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីលំនៅផ្ទះលេខ ១២៨ CE₀E₁ ផ្លូវ១២២ សង្កាត់ទឹកល្អក់ I ខណ្ឌទួលគោក ក្រុង ភ្នំពេញ ។

ផ្ទេរសិទ្ធិអោយឈ្មោះ កែវ សាវ៉ាត (កូនប្រសារ) ជាតំណាង

-និង ចុងចម្លើយឈ្មោះ សុខ ភា ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរ គ្រូបង្រៀន មានទីលំនៅ

ផ្ទះលេខ១២៨ $CE_0E_1$ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ក្រុង ភ្នំពេញ ។ ឪពុកឈ្មោះសុខ គឹមហោក់ "រស់" ម្តាយឈ្មោះ ហុក នាង "រស់" ។

មានមេធាវីលោក វ៉ែន ពៅ

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងទាមទារផ្ទះ

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ៤៥ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ របស់មេធាវី លោក ឈិត បូរ៉ាវុធ ប្តឹងមិនសុខចិត្តនិង សាលដីការដ្ឋប្បវេណីលេខ១១១ "គ" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូល នៃសេចក្តីសំរេច ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទិ ២១ ខែមីនា ឆ្នាំ១៩៩៦ របស់ឈ្មោះ សុខ សារុន ប្តឹងទាមទារផ្ទះ ពីឈ្មោះ សុខ ភា ដោយសំអាងហេតុថា កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៦ ខ្លួនបានផ្ញើផ្ទះលេខ១២៨ $CE_0E_1$ ឱ្យក្មួយប្រុសឈ្មោះ សុខ ជា ដើម្បីមើលថែរក្សាឱ្យខ្លួនដោយទៅព្យាបាលជំងឺនៅប្រទេសបារាំង ។ លុះបានរយៈពេល ១ខែស្រាប់តែ ឈ្មោះសុខ ភា បានគាស់សោរផ្ទះរបស់ខ្លួន ហើយចូលស្នាក់នៅតែដោយដេញ ក្មួយរបស់ខ្លួន ឈ្មោះសុខ ជា មិនអោយនៅលើផ្ទះនោះដែរ ពេលខ្លួនត្រឡប់មកពីប្រទេសបារាំងវិញឈ្មោះ សុខ ភា ក៏ដេញខ្លួនមិនឱ្យនៅហើយគំរាមកំហែងខ្លួនទៀត ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៣១ "ខ" ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ សុខ សារុន ចុះថ្ងៃទី ២១-០៣-៩៦ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលការផ្ទេរសិទ្ធិរបស់ឈ្មោះ សុខ សារុន ទៅអោយឈ្មោះទេស សាមឿន ចុះថ្ងៃទី ២៤ -០៤-៩៧ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣-ទទួលពាក្យបណ្តឹងសារត្រឡប់ របស់ចុងចម្លើយ ចុះថ្ងៃទី ១៧-១០-៩៦ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយពីគតិច្បាប់ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់៧០០០រៀល ដែលចុងចម្លើយ បានបង់រួចមកហើយ ។

៥-ផ្ទះលេខ ១២៨ $CE_0E_1$ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ត្រូវប្រគល់អោយឈ្មោះ សុខ សារុន ជាកម្មសិទ្ធិករចាប់ពីសាលក្រមចូលជាស្ថាពរ ។

៦-បង្គាប់អោយឈ្មោះសុខ ភា និងគ្រួសារចុះចេញពីផ្ទះលេខ ១២៨ $CE_0E_1$ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ចាប់ពីសាលក្រមមានប្រសិទ្ធិភាពអនុវត្ត ។

៧-បង្គាប់អោយចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីចំនួន ៧០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០រៀល ដែលដើមចោទបានបង់ទុករួចហើយ កាលបើហួសកំណត់ប្តឹងឧទ្ធរណ៍បង្គាប់អោយចុងចម្លើយសងប្រាក់ ៧០០០រៀល នេះទៅអោយដើមចោទវិញ និង បង្គាប់អោយឈ្មោះ សុខ ភា បង់ពន្ធសមាមាត្រចំនួន ១ភាគរយ លើតំលៃផ្ទះ១១០តំលឹង ស្មើនឹង ១តំលឹង ១ជី មាសប្រាក់នេះ ត្រូវបង់ចូលថវិការដ្ឋ ៨០ភាគរយ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

៨-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវឧទ្ធរណ៍រយៈពេល ២ខែ ចាប់ពីថ្ងៃផុតកំណត់ប្តឹងទាស់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៣ "ខ" ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៧ របស់ឈ្មោះ សុខ ភា ដែលប្តឹងជំទាស់ នឹងសាលក្រមរដ្ឋប្បវេណីលេខ ៣១ "ខ" ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការបៀបលេខ ១២ ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-បង្គាប់អោយភាគីដើមចោទផ្តល់កិច្ចសន្យាលក់-ទិញ ផ្ទះជាច្បាប់ដើម ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ ១៩៩៣ មកតុលាការ តាមសេចក្តីត្រូវការ ។

២-បង្គាប់អោយស្ថាប័នជំនាញធ្វើកោសល្យវិច្ច័យនូវក្រយៅដៃរបស់អ្នកលក់ផ្ទះ ឈ្មោះហេង ដុកគាវ និង នាងសុខ ភា ដែលមាននៅលើលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៣ អោយបានច្បាស់លាស់សិនមុននឹងសំរេចដល់អង្គសេចក្តី ។

៣-បង្គាប់អោយយកចម្លើយសាក្សីបន្ថែមទៀត កាលបើយល់ថាចាំបាច់ ។

៤-បង្គាប់អោយចុងចម្លើយចេញសោហ៊ុយក្នុងការអង្កេតនេះ ។ សាលដីការបៀបនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ។

បានឃើញសាលដីកាលេខ១៨៦ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍របស់នាងសុខ ភា ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមលេខ ៣១ "ខ" ចុះថ្ងៃទី១៥-៥-៩៧ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។ ផ្ទះលេខ១២៨ $CE_0E_1$ លេខ ១២២ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានវិញ្ញាបនប័ត្រសំគាល់អចលនវត្ថុលេខ១៣១៦២ ចុះថ្ងៃទី២១-១២-៩២ ត្រូវចែកតាមចំណែកដែលបាន

វិញ ដូចតទៅ: នាង សុខ ភា ត្រូវបាន៦៤,៧៩ ភាគរយ ។ នាង សុខ សារុន ត្រូវបាន ៣៥ .២១ ភាគរយ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ដែល នាង សុខ ភា បានបង់រួចហើយ គឺពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តី ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ ដីកាកោះ ៥០០០រៀល និងចំណាយលើអាជ្ញាធរ តុលាការ ៥០០០រៀល សរុប១៣.០០០រៀល ។ កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់អោយឈ្មោះ នាង សុខ សារុន សងប្រាក់ ១៣.០០០រៀល នេះ អោយទៅ នាង សុខ ភា វិញ ។

បង្គាប់អោយ នាង សុខ សារុន បង់ពន្ធសមាមាត្រ ១ភាគរយ ទៅលើចំនួនប្រាក់ ៧៦.៧៤ តម្លឹងមាស ។

បង្គាប់អោយ នាង សុខ ភា បង់ពន្ធសមាមាត្រ ១ភាគរយ: ទៅលើចំនួនប្រាក់៣៧.២៦ តម្លឹងមាស ។

ប្រាក់ពន្ធនេះ ៨០ភាគរយ ត្រូវបានជាប្រយោជន៍ថវិកាជាតិ និង ២ភាគរយ ត្រូវបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណ: ចំពោះមុខ នាង សុខ ភា កំបាំងមុខ ឈ្មោះ សុខ សារុន បើកផ្លូវទាស់ និង សាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១២១ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ១៩៩៨ របស់ឈ្មោះ សុខ សារុន ប្តឹងមិនសុខចិត្ត និងសាលដីការដ្ឋប្បវេណីលេខ១៨៦ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧៧ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ ១២១ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៩៨ របស់អ្នកស្រី សុខ សារុន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃ:សាលដីការដ្ឋប្បវេណីលេខ ១៨៦ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩៨ របស់សាលា - ឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២១៨ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលអ្នកស្រី សុខ ភា បានបង់ជូស គឺ:

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន១៥.០០០រៀល សរុប ១៩.០០០រៀល ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៩ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣៩៣ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេច ដូចតទៅ :

១-សម្រេចទទួលជំនុំជំរះ រឿងក្ដីនេះ ឡើងវិញតាមអំណាចសាលដីកាលេខ ៧៧ / ២២-៤-៩៩ របស់តុលាការកំពូល ។

២-សម្រេចតំកល់សាលក្រមលេខ ៣១ "ខ" ចុះថ្ងៃទី១៥-៥-៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ហើយ បើកផ្លូវប្ដឹងទាស់ និងប្ដឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់លេខ ៦៦ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០០ របស់ឈ្មោះ សុខ ភា មិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ៣៩៣ ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១១១ "គ" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១-មិនទទួលជំនុំជំរះ លើបណ្ដឹងទាស់ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០០ របស់ឈ្មោះ សុខ ភា ដោយបណ្ដឹងនេះ ហួសកំណត់ច្បាប់ ។

២-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខឈ្មោះកែវ សារ៉ាត ( ដើមចោទ ) មេធាវីការពារចុងចម្លើយ កំបាំងមុខ ចុងចំលើយ ។ បើកផ្លូវសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលើកទី២ លេខ៤៥ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ របស់មេធាវី លោក ឈិត បូរ៉ាវុធ ប្ដឹងមិនសុខចិត្តនិង សាលដីការដ្ឋប្បវេណីលេខ១១១ "គ" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូល នៃសេចក្ដីសំរេច ។

បានឃើញសាលដីការបៀបរបស់តុលាការកំពូល លេខ ៥៩ ចុះថ្ងៃទី ១៨ ខែមិនា ឆ្នាំ២០០៣ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេច ដូចតទៅ :

១-ចាត់របៀបឱ្យធ្វើការស៊ើបអង្កេតបន្ថែម ។

២-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០០៣ ។

បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ ថា:

-បណ្ដឹងសាទុក្ខរបស់ចុងចម្លើយស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យ ពិចារណា ។

-រឿងនេះ តុលាការកំពូលបានចេញសាលដីការបៀបលេខ ៥៩ ចុះថ្ងៃទី ១៨ ខែមិនា ឆ្នាំ ២០០៣ ដើម្បីធ្វើការសាកសួរ បន្ថែមជុំវិញបញ្ហាទំនាស់ផ្ទះ ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និង សំរេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សុខ ភា នាពេលសវនាការ បានឆ្លើយបញ្ជាក់ថា : ខ្លួនសុំបញ្ជាក់មុខតុលាការថាបាំ របស់ខ្លួនបានប្រគល់មាសចំនួនចិតសិបមួយតម្លឹងពីរជី ប្រាំហ៊ុន ឱ្យទៅអ្នកស្រីសុខ សារុន ពិតប្រាកដដោយមានលិខិតប្រគល់ត្រឹមត្រូវ ប៉ុន្តែខ្លួនពុំបានដាក់ចូលក្នុងសំណុំរឿងទេ ទើបតែបារបស់ខ្លួនផ្ញើពីស្រុកបារាំង បានខ្លួនរកឃើញលិខិតនេះ ។

សូមឯកឧត្តមប្រធានតុលាការ មេត្តាជួយរកយុត្តិធម៌ ឱ្យខ្លួន ផង ។

បានស្តាប់ចម្លើយរបស់ឈ្មោះកែវ សាវ៉ាត ខ្លួនជាតំណាងអោយអ្នកស្រី សុខ សារុន បានឆ្លើយថា : ពាក្យដែលឈ្មោះ សុខ ភា បានលើកឡើងនេះ គឺជាពាក្យមិនពិត ឡើយខ្លួនសុំបដិសេធចោលទាំងស្រុង ខ្លួនសុំទទួលស្គាល់តែលិខិតទិញលក់ផ្ទះ ព្រោះការទិញផ្ទះនេះ អ្នកស្រី សុខ សារុន ពិតជាបានទិញតែម្នាក់ឯង មិនបានទិញចូលជាមួយឈ្មោះ សុខ ភា ឡើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាសំរេចតំកល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកវ៉ែន ពៅ ជាមេធាវីការពារអោយអ្នកស្រីសុខ ភា ( ដើមចោទ ) បានធ្វើសេចក្តីសន្និដ្ឋានថា: បន្ទាប់ពីបានស្តាប់ចម្លើយរបស់គូភាគីមកឃើញថា អ្នកស្រី សុខ សារុន បានទិញផ្ទះនេះ តែម្នាក់ឯង គឺជាការពុំត្រឹមត្រូវឡើយ ព្រោះកូនក្តីរបស់ខ្លួនបានមានចំណែកចូលរួមទិញផ្ទះនេះដែរ ដោយមានលិខិតប្រគល់ប្រាក់ លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងមានប័ណ្ណគ្រួសារសុទ្ធតែមានការទទួលស្គាល់ពីរដ្ឋអំណាចមូលដ្ឋានទាំងអស់ ដោយសំអាងលើលិខិតទាំងអស់នេះ ហើយបានជាសាលាឧទ្ធរណ៍សំរេចឱ្យចែកតាមការទិញចូលគ្នា គឺ ឈ្មោះ សុខ ភា ត្រូវទទួលបាន៦៤.៧៥ ភាគរយ ចំណែកឈ្មោះ សុខ សារុន ទទួលបានតែ ៣៥.២១ ភាគរយ តែប៉ុណ្ណោះ ។ ដូច្នេះ សូម ឯកឧត្តម មេត្តាសំរេច តាមសាលដីកា របស់សាលាឧទ្ធរណ៍លើកទីមួយ វិញ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយ របស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី ចុងចម្លើយ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៥ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០០២ របស់លោកឈិត បូរ៉ាវុធ មេធាវីការពារឱ្យចុងចម្លើយ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាម

មាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអនុភាពអនុវត្តលើរឿងក្តីរដ្ឋប្បវេណីផងដែរ ។

-យល់ឃើញថា ការដែលចុងចម្លើយ និងមេធាវី លើកឡើងនៅពេលសវនាការនេះថា ឪពុកចុង-ចម្លើយ បានទិញផ្ទះទំនាស់ចូលគ្នាជាមួយដើមចោទ ដោយផ្អែកតាមកិច្ចសន្យាផ្ទេរសិទ្ធិគ្រប់គ្រងផ្ទះ ដែលមានបញ្ជាក់ ពីប្រធានសង្កាត់ទឹកល្អក់ទី១ ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ១៩៩៣ នោះតុលាការកំពូលពុំអាចទទួលស្គាល់បានទេ ពីព្រោះ កិច្ចសន្យានេះ ពុំមានហត្ថលេខាអ្នកស្រីសុខ អ៊ុំសារុន ពុំមានបញ្ជាក់ពីតម្លៃពុំមានបញ្ជាក់ពីចំនួនមាស ដែលគូភាគីម្នាក់ៗ ត្រូវប្រគល់ទេ ហើយអ្នកស្រី កាក់ វ៉ាន់ឌី ក៏បានធ្វើលិខិតសុំបដិសេធស្នាមមេដៃរបស់អ្នកស្រី និងប្តីអ្នកស្រីលើកិច្ចសន្យានេះ ហើយដែរ ។ម្យ៉ាងទៀត តាមកិច្ចសន្យាចុះថ្ងៃទី០៦ ខែមិនា ឆ្នាំ១៩៩៣ អ្នកស្រី សុខ អ៊ុំ សារុន បានទិញផ្ទះទំនាស់ពីអ្នកស្រីកាក់ វ៉ាន់ឌី និងលោក ហេង ជុកគារ ព្រមទាំងបានប្រគល់ មាសថ្លៃផ្ទះតែម្នាក់ឯង និងបានបំពេញបែបបទ តាមលិខិតលក់ផ្តាច់ និងផ្ទេរឈ្មោះពីបណ្ណ័កម្មសិទ្ធិ ជូនមកអ្នក ស្រី តាមរូបមន្តយថាភូត ត្រឹមត្រូវតាមមាត្រា ១៨២ នៃច្បាប់ភូមិបាលចាស់ហើយ ។

-យល់ឃើញថា ការដែលអ្នកស្រី សុខ ភា និងមេធាវីរបស់អ្នកស្រីលើកឡើងនៅក្នុងសារណា និងនៅពេលសវនាការនេះថា ផ្ទះទំនាស់លេខ១២៨$CE_0$-$E_1$ នេះ គឺទិញដោយមានការចូលហ៊ុនគ្នារវាងអ្នកស្រីសុខ -សារុន និងឪពុករបស់អ្នកស្រីដោយផ្អែកតាមលិខិតប្រគល់មាសទិញផ្ទះ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ១៩៩៣ នោះតុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះ តំណាងដើមចោទមិនទទួលស្គាល់លិខិតប្រគល់មាស ទិញផ្ទះចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ១៩៩៣ ទេ ហើយតាមលិខិតប្រកាសលទ្ធផលកោសល្យវិច័យ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៣ របស់នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ ទៅលើហត្ថលេខា ឈ្មោះ សុខ អ៊ុំសារុន លើលិខិតប្រគល់មាសទិញផ្ទះ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ១៩៩៣ និងគំរូហត្ថលេខា របស់អ្នកស្រី ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៣ សងតាមការពិនិត្យប្រៀបធៀបធ្វើកោសល្យវិច័យ នៅក្រោមកែវពង្រីក ប៉េអេស៩១ និងម៉ាស៊ីនប្រៀបធៀប លទ្ធផលទទួលបានគឺ : លក្ខណៈពិសេសរួម និងលក្ខណៈពិសេសដោយឡែករបស់ហត្ថ-លេខា បានបង្ហាញពីចំណុច ទំរង់ ដំណោក ទ្រង់ទ្រាយ តួអក្សរ ចំណុចផ្តើម ចំណុចបន្ត និងតភ្ជាប់នៃចលនាសំណេរ រវាងហត្ថលេខា គំរូ និងហត្ថលេខាលើខិលិតប្រគល់មាសទិញផ្ទះ ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ១៩៩៣ គឺ មិនមែនហត្ថលេខា អ្នកស្រី សុខ សារុន ឬ សុខ អ៊ុំ សារុន ទេ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណី លេខ ១១១ "គ" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទំរង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី**

៨

១-ទទួលបណ្ដឹងសាទុក្ខលេខ ៤៥ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ របស់លោក ឈិត បូរ៉ាវុធ ការពារឱ្យចុងចម្លើយ ទុកជាត្រឹមត្រូវ តាមទំរង់ និងគតិច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស និងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ១១១ "គ" ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីដែលដើមចោទ បានបង់ជូសនៅតុលាការកំពូល ចំនួន ១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្ដី និងពន្ធប្ដឹង ចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។ ហើយ តំរូវ ឱ្យ ចុងចម្លើយសងប្រាក់ ចំនួន ១៩.០០០រៀល នេះ ទៅដើមចោទវិញ ។

បង្គាប់ឱ្យចុងចម្លើយ បង់ពន្ធសមាមាត្រ១ភាគរយ លើតម្លៃជាក់ស្តែង នៃផ្ទះចំនាស់ ។

២-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៣ ។